# គុណភាពពូជស្រូវ និងគុណភាពជីវិតរបស់កសិករ

ការជ្រើសរើស និងទុកដាក់ពូជស្រូវដោយខ្លួនឯង ជាកត្តាមួយចាំបាច់ក្នុងការធានាអោយស្រូវលូតលាស់បានផលល្អ និងធ្វើឲ្យកសិករមិនមានភាពអាស្រ័យលើពូជមកពីខាងក្រៅ ។ ក៏ប៉ុន្តែកន្លងមក ខ្ញុំសង្កេតឃើញថាកសិករយើងភាគច្រើននៅមិនទាន់អនុវត្តការជ្រើសរើស និងទុកដាក់ពូជបានល្អ ។ នៅពេលនេះ ខ្ញុំសូមលើកយកមកនូវចំណុចខ្វះខាតសំខាន់ៗមួយចំនួនមកបង្ហាញជូន ក៏ដូចជាផ្តល់នូវគំនិតកែលំអបន្ថែម ។

ចំណុចខ្វះខាតមួយចំនួនក្នុងការជ្រើសរើស និងទុកដាក់ពូជស្រូវមានដូចខាងក្រោមនេះ



- កសិករភាគច្រើនមិនមានការបែងចែកនូវស្រូវពូជ និងស្រូវចំណីទេក្នុងការដាំដុះថៃទាំទេ
- កសិករមួយចំនួនមិនបានធ្វើការជ្រើសរើសកន្លែង ឬ គុម្ពស្រូវណាដែលមានលក្ខណៈល្អពិសេសជាងគេសម្រាប់ទុកពូជទេ
- ស្រូវទុកពូជត្រូវបានយកទៅបោកបែនដូចស្រូវធម្មតាដែលបណ្តាលអោយមានការប៉ះពាល់ដល់ពន្លកស្រូវដែលស្ថិតនៅក្នុងគ្រាប់ស្រូវ (ពន្លកស្រូវនេះប្រៀបដូចជាកូនង៉ែតនៅក្នុងគ្រាប់ស្រូវ)
- នៅពេលទុកដាក់ពូជគេច្រើនទុកក្នុងបាវ ឬ ក្នុងជង្រុកដែលមិនមានខ្យល់ចេញចូលបានល្អ និងមានកម្តៅខ្លាំងជាពិសេសសម្រាប់គ្រាប់ពូជស្រូវនៅកណ្តាលគេ ។

តាមរយៈការអនុវត្តខាងលើនេះ ជាពិសេស ការបោកបែន និងការទុកដាក់គ្រាប់ស្រូវពូជដោយគ្មានគិតគូដល់ជីវិតរបស់ពន្លកកូនស្រូវនៅក្នុងគ្រាប់វាអាចបណ្តាលអោយកូនស្រូវដែលដុះចេញមកមិនសូវមានសុខភាពល្អ ។

លើសពីនេះទៀត នៅពេលសាប គេសាបយ៉ាងចង្អៀត ហើយពេលស្ទូងក៏ចាប់ច្រើនដើម និងការស្ទូងកប់ឫសយ៉ាងជ្រៅដែលបណ្តាលអោយកូនស្រូវមានការលំបាកក្នុងការលូតលាស់ ។ ជាលទ្ធផល ស្រូវមិនសូវលូតលាស់បានល្អហើយងាយទទួលការបំផ្លាញពីសត្វល្អិត និងជំងឺ ។

ដើម្បីអាចអោយយើងទទួលផលស្រូវបានច្រើន ក្រៅពីការបង្កើននូវជីជាតិដី ជាពិសេសសារធាតុមមោកនៅក្នុងដីស្រែទាប់លើ និងការអនុវត្តបច្ចេកទេសតាមរបៀបប្រព័ន្ធប្រពលវប្បកម្ម ការជ្រើសរើស និងទុកដាក់ពូជជារឿងមួយដ៏សំខាន់ ឬ ដ៏សំខាន់បំផុត ។ ដូចនេះសម្រាប់រដូវប្រមូលផលខាងមុខនេះ សូមកសិករទាំងអស់យកចិត្តទុកដាក់ក្នុងការជ្រើសរើស និងទុកដាក់គ្រាប់ពូជស្រូវអោយបានល្អប្រសើរ ដូចជាធ្វើការពន្យូរទុកជាកួរៗតែម្តង ឬ ធ្វើការប្រឡេះគ្រាប់ពូជដោយដៃថ្នមៗ ហើយរក្សាទុកក្នុងថង់ក្រណាត់តូចៗដែលមានខ្យល់ចេញចូលបានល្អ។ ទោះបីវាទាមទារនូវពេលវេលា

ច្រើនបន្តិចមែនតែយើងត្រូវចាំថា គ្រាប់ពូជ ១ គ្រាប់ៗ អាចនាំមកនូវស្រូវ ២០-៣០ កួរ ឬ ៥០០០-៧០០០ គ្រាប់ ឬលើសនេះទៀត ។

"ពូជស្រូវជាជីវិតរបស់កសិករ ការបាត់បង់គុណភាពពូជស្រូវ
គឺបាត់បង់គុណភាពជីវិត ការបាត់បង់ពូជស្រូវ គឺបាត់បង់ជីវិត"

**បណ្ឌិត យ៉ង សាំងកុមារ**